**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ ៤៨៩/២២ ក. ស. ភ.

ថ្ងៃសុក្រ ១១ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព. ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០២២

# សេចក្ដីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)** មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា កាលពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ កន្លងមក ក. ស. ភ. បានជូនដំណឹងទៅ ក្រុមហ៊ុន ហ៊ុយ បាង អ៊ិនធើណេសិនណល អ៊ិនវេសមិ៉ន គ្រុប អំពីការទទួលយកនូវសំណើសុំផ្ទេរដីរបស់ក្រុមហ៊ុនដែលបានជួលពី ក. ស. ភ. ទំហំ ១៨.៨៣៦,៦៩ម៉ែត្រក្រឡា។ ការស្នើសុំផ្ទេរដីនេះ ដោយហេតុថាក្រុមហ៊ុនបានជួបប្រទះនូវវិបត្តិហិរញ្ញវត្ថុ ដែលពុំមានលទ្ធភាពក្នុងការទូទាត់ថ្លៃឈ្នួលដីជាប្រចាំខែជូន ក. ស. ភ.។

ក្នុងន័យនេះ ដើម្បីរក្សាប្រភពចំណូលដែលបានមកពីការជួលដី ក. ស. ភ. បានជួលបន្តនូវទំហំដីខាងលើឱ្យទៅក្រុមហ៊ុន ភីធីអិលអេស ខូអបភើរេសិន និង អ្នកស្រី លី ចាន់នី សម្រាប់រយៈពេល ៣៦ ឆ្នាំ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០៥៩។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ទទួលជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្ដាល: អគារលេខ ៦៤៩ តីរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh